**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ១៧៤៣.៥៣ ហិកតា ចេញពីក្រុមហ៊ុន រៀលហ្គ្រីន ទំហំ ១០៩២០.០២ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៥៨ គ្រួសារ និងដីទំហំ ៦៥១.៤៩ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង ផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៩៣៥ ក្បាលដី ក្នុងនោះជាកម្មសិទ្ធិឯកជនជូន ៧៤៩ គ្រួសារ លើ ៩៣២ ក្បាលដី និងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ (សាលារៀន) ០៣ ក្បាលដី នៅក្រុងសំរោង ខេត្តឧត្តរមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២១២៥ ឧជ ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តឧត្តរមានជ័យ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.**

ត្រូវបានកាត់ដីសរុបទំហំ ១.៧៤៣,៥៣ ហិកតា ដែលក្នុងនោះកាត់ចេញពីក្រុមហ៊ុន រៀលហ្គ្រីន ទំហំ ១.០៩២,០២ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ៦៥១,៤៩ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅសង្កាត់បន្សាយរាក់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ដែលស្ថិតនៅក្នុងភូមិដូចខាងក្រោម៖

១. ទំហំ ៥៣២,១៣ ហិកតា កាត់ចេញពីក្រុមហ៊ុនរៀលហ្គ្រីន ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវដីទំហំ ៣២០,៩៣ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ២១១,២ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលស្ថិតនៅភូមិខ្នាច់ឫស្សី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ។

២. ទំហំ ១.២១១,៤០ ហិកតា កាត់ចេញពីក្រុមហ៊ុនរៀលហ្គ្រីន ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវដីទំហំ ៧៧១,១១ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូន

ប្រជាពលរដ្ឋ និងដីទំហំ ៩៩០,២៩ ហិកតា រក្សាទុកសម្រាប់ជាដីសាធារណៈរបស់រដ្ឋ នៅភូមិកសិទេពពោធិវង្ស តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៧៥៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅសង្កាត់បន្សាយរាក់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ដែលរួមមាន ៖

១. ផ្ទៃដីកាត់ចេញពីក្រុមហ៊ុនវៀលហ្វ៊ីន ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣២៧ គ្រួសារ នៅភូមិខ្នាច់ឬស្សី

២. ផ្ទៃដីកាត់ចេញពីក្រុមហ៊ុនវៀលហ្វ៊ីន ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៣១ គ្រួសារ នៅភូមិកសិទេពពោធិវង្ស ។

**មាត្រា ៣ .-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៩៣៥ ក្បាលដី ក្នុងនោះផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៧៤៩ គ្រួសារ លើក្បាលដីចំនួន ៩៣២ ក្បាលដី និងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ (សាលារៀន) ០៣ ក្បាលដី នៅក្នុងភូមិដូចខាងក្រោម ៖

១. ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៤៣៣ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៣២៧ គ្រួសារ នៅភូមិខ្នាច់ឬស្សី

២. ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៤៩៩ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៤២២ គ្រួសារ និងជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋ (សាលារៀន) ០៣ ក្បាលដី នៅភូមិកសិទេពពោធិវង្ស ។

**មាត្រា ៤ .-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.........អនក្រ.បក ចុះថ្ងៃទី.....០៣.....ខែ.....ធ្នូ.....ឆ្នាំ២០១២ ស្តីពីការកាត់ដីសរុបទំហំ ១.៧៤៣,៥៣ ហិកតា ចេញពីក្រុមហ៊ុនវៀលហ្គ្រីន ទំហំ ១.០៩២,០២ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៩៨ គ្រួសារ និងដីទំហំ ៦៥១,៤៩ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៩៣៥ ក្បាលដី ក្នុងនោះជូនជាកម្មសិទ្ធិឯកជន ៧៤៩ គ្រួសារ លើ ៩៣២ ក្បាលដី និងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ០៣ ក្បាលដី (សាលារៀន) នៅក្រុងសំរោង ខេត្តឧត្តរមានជ័យ




| ចំនុច | អាប់ស៊ីស | អរដោណេ | ចំនុច | អាប់ស៊ីស | អរដោណេ |
|---|---|---|---|---|---|
| 1 | 341771 | 1588825 | 35 | 341852 | 1585659 |
| 2 | 342145 | 1588879 | 36 | 341733 | 1585732 |
| 3 | 343172 | 1588670 | 37 | 341877 | 1585859 |
| 4 | 343088 | 1588495 | 38 | 341812 | 1585963 |
| 5 | 342993 | 1588438 | 39 | 341816 | 1586226 |
| 6 | 343057 | 1588257 | 40 | 341737 | 1586281 |
| 7 | 343165 | 1588195 | 41 | 341758 | 1586450 |
| 8 | 343210 | 1588123 | 42 | 341901 | 1586478 |
| 9 | 343008 | 1588081 | 43 | 341928 | 1586539 |
| 10 | 343025 | 1587871 | 44 | 341803 | 1586576 |
| 11 | 343264 | 1587823 | 45 | 341782 | 1586651 |
| 12 | 343264 | 1587743 | 46 | 341698 | 1586662 |
| 13 | 343318 | 1587719 | 47 | 341725 | 1586716 |
| 14 | 343254 | 1587448 | 48 | 341808 | 1586767 |
| 15 | 343432 | 1587460 | 49 | 341787 | 1586816 |
| 16 | 343403 | 1587317 | 50 | 341660 | 1586816 |
| 17 | 343277 | 1587157 | 51 | 341566 | 1586861 |
| 18 | 343451 | 1586950 | 52 | 341555 | 1586921 |
| 19 | 343631 | 1586938 | 53 | 341713 | 1586968 |
| 20 | 343696 | 1586872 | 54 | 341554 | 1587130 |
| 21 | 343735 | 1586739 | 55 | 341507 | 1587287 |
| 22 | 343802 | 1586631 | 56 | 341457 | 1587340 |
| 23 | 343784 | 1586573 | 57 | 341277 | 1587351 |
| 24 | 343676 | 1586470 | 58 | 341207 | 1587491 |
| 25 | 343584 | 1586419 | 59 | 341470 | 1587698 |
| 26 | 343569 | 1586323 | 60 | 341510 | 1587827 |
| 27 | 343526 | 1586258 | 61 | 341430 | 1587795 |
| 28 | 343443 | 1586288 | 62 | 341374 | 1587827 |
| 29 | 343369 | 1586227 | 63 | 341438 | 1588068 |
| 30 | 343450 | 1586121 | 64 | 341663 | 1588238 |
| 31 | 343160 | 1585795 | 65 | 341690 | 1588341 |
| 32 | 343114 | 1585727 | 66 | 341820 | 1588377 |
| 33 | 343097 | 1585604 | 67 | 341838 | 1588547 |
| 34 | 341853 | 1585608 | 68 | 341869 | 1588565 |
| 35 | 341852 | 1585659 | 69 | 341869 | 1588703 |
| 36 | 341733 | 1585732 | 70 | 341775 | 1588775 |

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៤.៧.៤.៧.អនក្រ.បក...ចុះថ្ងៃទី.....០៣......ខែ...ធ្នូ......ឆ្នាំ២០១២ ស្ដីពីការកាត់ដីសរុបទំហំ ១.៧៤៣,៥៣ ហិកតា ចេញពីក្រុមហ៊ុនវៀលហ្វ្រីន ទំហំ ១.០៩២,០២ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៩៨ គ្រួសារ និងដីទំហំ ៦៥១,៤៩ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៩៣៥ ក្បាលដី ក្នុងនោះជូនជាកម្មសិទ្ធិឯកជន ៧៤៩ គ្រួសារ លើ ៩៣២ ក្បាលដី និងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ០៣ ក្បាលដី (សាលារៀន) នៅក្រុងសំរោង ខេត្តឧត្តរមានជ័យ




ចំណោលផែនទី UTM(Universal Transvers Mercator), Zone 48N
ជាតទូមប៉ូងរាប WGS 84

| ចំនុច | អាប់ស៊ីស | អរដោណេ | ចំនុច | អាប់ស៊ីស | អរដោណេ |
|---|---|---|---|---|---|
| 1 | 339700 | 1586377 | 37 | 342029 | 1583830 |
| 2 | 339700 | 1586377 | 38 | 342235 | 1583868 |
| 3 | 340805 | 1586442 | 39 | 342363 | 1583356 |
| 4 | 341656 | 1586337 | 40 | 342215 | 1583330 |
| 5 | 341816 | 1586226 | 41 | 342157 | 1582924 |
| 6 | 341812 | 1585963 | 42 | 342218 | 1582806 |
| 7 | 341877 | 1585859 | 43 | 342146 | 1582670 |
| 8 | 341733 | 1585732 | 44 | 342135 | 1582323 |
| 9 | 341852 | 1585659 | 45 | 342184 | 1582250 |
| 10 | 341855 | 1585549 | 46 | 342196 | 1582042 |
| 11 | 341752 | 1585524 | 47 | 342264 | 1581951 |
| 12 | 341683 | 1585586 | 48 | 342289 | 1581814 |
| 13 | 341581 | 1585563 | 49 | 342502 | 1581514 |
| 14 | 341596 | 1585459 | 50 | 342121 | 1581442 |
| 15 | 341734 | 1585463 | 51 | 341686 | 1581445 |
| 16 | 341794 | 1585361 | 52 | 341563 | 1581606 |
| 17 | 341734 | 1585308 | 53 | 341544 | 1581558 |
| 18 | 341744 | 1585189 | 54 | 341354 | 1581640 |
| 19 | 341606 | 1585186 | 55 | 341330 | 1581555 |
| 20 | 341648 | 1585046 | 56 | 340903 | 1581524 |
| 21 | 341511 | 1584873 | 57 | 340691 | 1581415 |
| 22 | 341564 | 1584681 | 58 | 340803 | 1581432 |
| 23 | 341476 | 1584562 | 59 | 340761 | 1581586 |
| 24 | 341497 | 1584660 | 60 | 340689 | 1581581 |
| 25 | 341527 | 1584505 | 61 | 340694 | 1581538 |
| 26 | 341604 | 1584575 | 62 | 340524 | 1581532 |
| 27 | 341671 | 1584559 | 63 | 340530 | 1581383 |
| 28 | 341676 | 1584500 | 64 | 340410 | 1581441 |
| 29 | 341820 | 1584374 | 65 | 340366 | 1581579 |
| 30 | 341763 | 1584266 | 66 | 340190 | 1581630 |
| 31 | 341872 | 1584126 | 67 | 340087 | 1581462 |
| 32 | 341720 | 1584126 | 68 | 339622 | 1581509 |
| 33 | 341777 | 1584002 | 69 | 339356 | 1581472 |
| 34 | 341617 | 1583974 | 70 | 339595 | 1583856 |
| 35 | 341594 | 1583881 | 71 | 339431 | 1584574 |
| 36 | 341891 | 1583739 | 72 | 339385 | 1585446 |